### ប្រជុំថ្នាក់ខេត្តរបស់បុគ្គលិកគម្រោងឡជីវឧស្ម័ននៅខេត្តព្រៃវែងៈ

នៅថ្ងៃទី 0៤ ខែ ឧសភា ឆ្នាំ ២០១១ ក្រុមការងារប្រចាំខេត្តព្រៃវែងនៃបុគ្គលិកគម្រោងឡជីវឧស្ម័នរបស់អង្គការសេដាក បានរៀបចំកិច្ចប្រជុំមួយដើម្បីពិនិត្យមើលអំពីវឌ្ឍនៈភាពរបស់គម្រោង ឬលទ្ធផលការងារដែលគម្រោងសម្រេចបាន និងរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ ២០១១។ កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន ១៦នាក់ចូលរួម និងសម្របសម្រួលដោយលោកបណ្ឌិតយ៉ង សាំងកុមារ ប្រធានអង្គការសេដាក។ គិតត្រឹមខែមីនា ឆ្នាំ ២០១១នេះ សេដាកបានគាំទ្រឱ្យមានការសាងសង់ឡបានចំនួន ៨៨២ឡ នៅក្នុងខេត្តព្រៃវែងស្ថិតនៅក្នុងភូមិចំនួន ៣៤៧ភូមិ ៩៧ឃុំ និង ១២ស្រុក។